ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សង្គ្រាមព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៩២/២៥-០៥-២០២០
**សាលដីកា**
លេខ ០៣ ក្រវន
ចុះថ្ងៃទី២១-០១-២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

ឆ្នាំពីរពាន់ម្ភៃមួយ ខែធ្នូ ថ្ងៃម្ភៃបួន វេលាម៉ោង ប្រាំបី នាទីព្រឹក សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ បានបើកសវនាការជាសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ ៧៩២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ លើជនជាប់ចោទដែលមានដូចខាងក្រោម៖

ជនជាប់ចោទឈ្មោះ [redacted] **ធីតា** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] មានកូន ០៤ នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន។(ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤២៤៤ ដកបយឧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩។

ជាប់ចោទពីបទ៖ **មនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **មួន** ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រែកដំបង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។(បានដកពាក្យបណ្តឹង)

-លោកស្រី [redacted] **សុខា** លោកស្រី [redacted] **ហ៊្គិចហ្វួយ** និងលោក [redacted] **ឆវ័ន** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៥ ម៉ោងប្រហែល ០៩ យប់ ឈ្មោះ [redacted] មុត និងបងឈ្មោះ [redacted] មួន បាននាំគ្នាដើរទៅមើលគេចាក់ធុងបាស់រាំនៅភូមិត្បូងដំរី ក្នុងឃុំកំពង់ចម្លង ពេលទៅដល់កន្លែងរាំ ឈ្មោះ [redacted] មុត បានចូលទៅអង្គុយផឹកស្រាជាមួយឈ្មោះ [redacted] តេនា,ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស នៅខាងត្បូងសាលាធទានតួព្រះធាតុ ជិតវង់រាំ ដល់ម៉ោងប្រហែល ១១ និង ៣០នាទី បងរបស់ [redacted] មុត ឈ្មោះ [redacted] មួន ត្រឡប់ទៅផ្ទះមុន នៅម៉ោងប្រហែល ១១ និង ៣០នាទី ឈ្មោះ [redacted] ឆៃហាវ បានដើរទៅកន្លែងគ្រែដែលឈ្មោះ [redacted] មុត អង្គុយផឹកជាមួយឈ្មោះ [redacted] តេនា, ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស ពេលនោះ ឈ្មោះ [redacted] មុត បានចាក់ស្រាមួយកែវហុចឲ្យឈ្មោះ [redacted] ឆៃហាវ ផឹក លុះដល់ម៉ោង ១២ ឈ្មោះ [redacted] តេនា, ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នាដើរចេញទៅទិសខាងត្បូងបាត់ទៅ ពេលនោះឈ្មោះ [redacted] ឆៃហាវ ឃើញឈ្មោះ [redacted] មុត ស្រវឹងខ្លាំងក៏បានសុំជូនទៅផ្ទះ តែឈ្មោះ [redacted] មុត តបថា មិនអីទេសុទ្ធតែពួកម៉ាកខ្លួនទេ បន្ទាប់មកពួកគេទាំង ៤ នាក់នាំគ្នាដើរចេញពីកន្លែងផឹកបាត់អស់ទៅ ចាប់ពីពេលនោះមកឈ្មោះ [redacted] មុត បាត់ខ្លួនរហូតមិនឃើញចូលផ្ទះ លុះដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោងប្រហែល ៩ ព្រឹក ស្រាប់តែឃើញសាកសពឈ្មោះ [redacted] មុត អណ្តែតក្នុងទឹកព្រែកសំបួរ ដែលហូរចេញពីទន្លេតូច ស្ថិតក្នុងភូមិសំបួរ ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ហើយនៅលើសាកសពមានស្នាមជាំត្រង់កញ្ចឹងក ១កន្លែង ជាំលើចង្កេះ១កន្លែង និងស្នាមមុតលើខ្នង ៣កន្លែង ជាស្នាមមុតដោយអាវុធមុខស្រួច។ ក្រោយពីស្រង់សាកសពយកមកដល់ផ្ទះ ជនសង្ស័យឈ្មោះ [redacted] តេនា, ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នារត់គេចខ្លួនបាត់ពីផ្ទះរហូត។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម៖

១/ផ្តន្ទាទោស៖

ក-ជនជាប់ចោទឈ្មោះ [redacted] តេនា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និង បច្ចុប្បន្ននៅភូមិជ្រោយ [redacted] ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ទោសពីមុនគ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

ខ-ជនជាប់ចោទឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និង បច្ចុប្បន្ននៅភូមិ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ទោសពីមុនគ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

គ-ជនជាប់ចោទឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និង បច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ទោសពីមុន គ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។



CamScanner

ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-បង្គាប់ឲ្យឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] ធីតា រួមគ្នាសងជម្ងឺចិត្តប្រាក់ចំនួន ១៥ លាន រៀល ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន។ ដើមបណ្ដឹងទាមទារលើសពីនេះបដិសេធចោល

៣-ចេញដីកាចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រតនា, ឈ្មោះ [redacted] ធីតា និងជនជាប់ចោទឈ្មោះ [redacted] ប្រុស គិតពីថ្ងៃប្រកាសសាលក្រមតទៅ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារឲ្យជនជាប់ចោទ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រតនា, [redacted] ធីតា និងឈ្មោះ [redacted] ប្រុស និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន

-ទុកសិទ្ធិប្ដឹងទាស់ នឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បានឃើញ** សាលក្រមសម្រេចលើបណ្ដឹងទាស់លេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម៖

១.ទទួលបណ្ដឹងទាស់របស់ឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ ៣៥ឆ្នាំ ទុកជាត្រឹមត្រូវតាមផ្លូវច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីតា។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ត្រង់ចំណុច នៃសេចក្ដីសម្រេចទាំងមូល។

**បានឃើញ** របាយការណ៍របស់សាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។

**បានឃើញ** សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។

## នាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ អានរបាយការណ៍ក្នុងសំណុំរឿង។

-ជនជាប់ចោទឈ្មោះ [redacted] ធីតា បានឆ្លើយថា បានជាខ្លួនប្ដឹងឧទ្ធរណ៍មកនេះ ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ រូបខ្លួនទើបតែត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៩ កន្លងមកខ្លួននៅផ្ទះរហូតដោយមិនបានរត់គេចខ្លួនទៅណាទេ ដោយខ្លួននៅស្រុករហូតមិនដែលបានរត់ទៅណាទេ។ រីឯ អ្នកទាំង ២ (ពីរ) នាក់ ទៀតបានរត់ទៅក្រៅស្រុកអស់ហើយ។ នៅមុនពេលកើតហេតុ ខ្លួនពិតជាបានផឹកជាមួយជនរងគ្រោះពិតមែន ខ្លួនអត់បានទៅផ្ទះជាមួយជនរងគ្រោះទេ ហើយខ្លួនក៏អត់ដែលមានជម្លោះជាមួយគ្នាដែរ។ ពេលផឹកស្រាជាមួយគ្នានោះគ្មានអ្នកណាចេញលុយទេ ពីព្រោះថា ស្រានៅទីនោះមានស្រាប់។ ចំពោះខ្លួននៅពេលដែលដឹងថា ជនរងគ្រោះបានស្លាប់ ខ្លួននៅផ្ទះហើយក៏បានទៅបុណ្យសពនោះដែរ។ ចំពោះខ្លួនមិនបានចូលលុយបុណ្យទេ ប៉ុន្តែ ម៉ែខ្លួនជាអ្នកចូលលុយបុណ្យសព តែខ្លួនមិនដឹងប៉ុន្មានទេ។ រីឯ ចម្លើយដែលខ្លួនបានឆ្លើយនៅសាលាដំបូងខ្លួនមិនបានចាំទេ។ ខ្លួនមិនបានសម្លាប់ជន

រងគ្រោះ ទេ ចំពោះឈ្មោះ [redacted] វ៉ុន ខ្លួនមិនស្គាល់ទេ។ ហេតុដូចនេះ សំណូមពរសូមសាលាឧទ្ធរណ៍សម្រេចលើកលែងការចោទប្រកាន់។

-លោក លោកស្រី [redacted] សុខា លោកស្រី [redacted] ហ៊ួចហួយ និងលោក [redacted] ចវ៉ែ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ការសម្រេចដាក់ទោសកូនក្តីខ្លួនគឺមានភាពអយុត្តិធម៌ ដោយហេតុថាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ធីតា រូបនេះអត់បានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ។ ពីព្រោះថា អត់មានកស្តុតាង ឬ សាក្សីណាមួយ ដែលបានឆ្លើយដាក់បន្ទុកមកលើកូនក្តីខ្លួនថា កូនក្តីខ្លួនបានប្រព្រឹត្តទេ។ នៅពេលដែលកូនក្តីខ្លួនត្រូវបានចាប់ឃាត់ខ្លួន កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ធីតា នេះអត់បានដឹងអ្វីទាំងអស់ ហើយគន្លងមកចំពោះខាងតុលាការក៏មិនបានចេញ ដីកាកោះឬដីកាបញ្ជាឲ្យចូលខ្លួននោះដែរ ហើយបើតាមបងរបស់ជនរងគ្រោះក៏បានដកពាក្យបណ្តឹងហើយដែរ។ ចំពោះខ្លួនសូមគាំទ្រការសន្និដ្ឋានរបស់តំណាងអយ្យការឲ្យធ្វើការចាត់របៀប និង សូមសំណូមពរឲ្យកូនក្តីខ្លួនបានរួចផុតពីបទចោទប្រកាន់លើកូនក្តីរបស់ខ្លួន។

-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បានឲ្យដឹងថា ក្រោយពីបានពិភាក្សាគ្នាដេញដោលរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ធីតា បានឆ្លើយបដិសេធថា ជនជាប់ចោទមិនបានប្រព្រឹត្តទេ រីឯ កស្តុតាងឬសាក្សីក៏អត់បានឃើញច្បាស់ដែរ។ ប៉ុន្តែ ចំពោះឈ្មោះ [redacted] វ៉ុន ដែលបានឃើញថាហេតុការណ៍នោះ ត្រង់ចំណុចនេះសូម ឲ្យក្រុមប្រឹក្សាពិចារណា និងជនជាប់ចោទថាអត់បានទៅណាទេ ត្រង់ចំណុចនេះគួរកត់សម្គាល់ផងដែរ។ ដូច្នេះសូមឲ្យធ្វើការចាត់របៀប ដើម្បីដឹងថាជនជាប់ចោទឈ្មោះ [redacted] ធីតា ពិតជាបានមិនបានរត់ទៅទីណា ហើយឲ្យសាកសួរទៅខាងភូមិ-ឃុំ និងសមត្ថកិច្ចថា តើជនជាប់ចោទឈ្មោះ [redacted] ធីតា ពិតជានៅផ្ទះឬក៏អត់? បន្ទាប់ពីបានដឹងថាជនរងគ្រោះត្រូវបានស្លាប់ហើយនោះ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ការកត់សម្គាល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. បណ្តឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ត្រូវបានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ភ្នំពេញ អាចទទួលជំនុំជម្រះជាសមត្ថកិច្ចបាន យោងតាមបញ្ញត្តិមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ធីតា ដែលបានឆ្លើយនាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញបានឲ្យដឹងថា បានជាខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់



CamScanner

ទេ។ រូបខ្លួនទើបតែត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ កន្លងមកខ្លួននៅផ្ទះរហូត ដោយមិនបានរត់គេចខ្លួនទៅណាទេ ដោយខ្លួននៅស្រុករហូតមិនដែលបានរត់ទៅណាទេ។ រីឯ អ្នកទាំង ២ (ពីរ) នាក់ ទៀតបានរត់ទៅក្រៅស្រុកអស់ហើយ។ នៅមុនពេលកើតហេតុ ខ្លួនពិតជាបានផឹកជាមួយ ជនរងគ្រោះពិតមែន ខ្លួនអត់បានទៅផ្ទះជាមួយជនរងគ្រោះទេ ហើយខ្លួនក៏អត់ដែលមានជម្លោះជាមួយ គ្នាដែរ។ ពេលផឹកស្រាជាមួយគ្នានោះគ្មានអ្នកណាចេញលុយទេ ពីព្រោះថា ស្រានៅទីនោះមានស្រាប់។ ចំពោះខ្លួននៅពេលដែលដឹងថា ជនរងគ្រោះបានស្លាប់ ខ្លួននៅផ្ទះហើយក៏បានទៅបុណ្យសពនោះដែរ។ ចំពោះខ្លួនមិនបានចូលលុយបុណ្យទេ ប៉ុន្តែ ម៉ែខ្លួនជាអ្នកចូលលុយបុណ្យសព តែខ្លួនមិនដឹងប៉ុន្មានទេ។ រីឯ ចម្លើយដែលខ្លួនបានឆ្លើយនៅសាលាដំបូងខ្លួនមិនបានចាំទេ។ ខ្លួនមិនបានសម្លាប់ជនរងគ្រោះ ទេ ចំពោះឈ្មោះ [redacted]វ៉ុន ខ្លួនមិនស្គាល់ទេ។ ហេតុដូចនេះ សំណូមពរសូមសាលាឧទ្ធរណ៍សម្រេចលើក លែងការចោទប្រកាន់។

៣. មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើការកត់សម្គាល់ នាពេលសវនាការនៅសាលាឧទ្ធរណ៍ ភ្នំពេញ បានឲ្យដឹងថា ការសម្រេចដាក់ទោសកូនក្តីខ្លួនគឺមានភាពអយុត្តិធម៌ ដោយហេតុថា កូនក្តីរបស់ខ្លួន ឈ្មោះ [redacted] ធីតា រូបនេះអត់បានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ។ ពីព្រោះថា អត់មានភស្តុតាង ឬ សាក្សីណាមួយ ដែលបានឆ្លើយដាក់បន្ទុកមកលើកូនក្តីខ្លួនថា កូនក្តីខ្លួនបានប្រព្រឹត្តទេ។ នៅពេល ដែលកូនក្តីខ្លួនត្រូវបានចាប់ឃាត់ខ្លួន កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ធីតា នេះអត់បានដឹងអ្វីទាំងអស់ ហើយ កន្លងមកចំពោះខាងតុលាការក៏មិនបានចេញ ដីកាកោះឬដីកាបញ្ជាឲ្យចូលខ្លួននោះដែរ ហើយបើតាម បងរបស់ជនរងគ្រោះក៏បានដកពាក្យបណ្តឹងហើយដែរ។ ចំពោះខ្លួនសូមគាំទ្រការសន្និដ្ឋានរបស់តំណាង អយ្យការឲ្យធ្វើការចាត់របៀប និង សូមសំណូមពរឲ្យកូនក្តីរបស់ខ្លួនបានរួច ផុតពីបទចោទប្រកាន់លើ កូនក្តីរបស់ខ្លួន។

៤. តំណាងមហាអយ្យការបានធ្វើការកត់សម្គាល់នាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បានឲ្យដឹងថា ក្រោយពីបានពិភាក្សាគ្នាដេញដោលរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted]ធីតា បានឆ្លើយបដិសេធ ថា ជនជាប់ចោទមិនបានប្រព្រឹត្តទេ រីឯ ភស្តុតាងឬសាក្សីក៏អត់បានឃើញច្បាស់ដែរ។ ប៉ុន្តែ ចំពោះ ឈ្មោះ [redacted] វ៉ុន ដែលបានឃើញថាហេតុការណ៍នោះ ត្រង់ចំណុចនេះសូម ឲ្យក្រុមប្រឹក្សាពិចារណា និង ជនជាប់ចោទថាអត់បានទៅណាទេ ត្រង់ចំណុចនេះគួរកត់សម្គាល់ផងដែរ។ ដូច្នេះសូមឲ្យធ្វើការចាត់ របៀប ដើម្បីដឹងថាជនជាប់ចោទឈ្មោះ[redacted]ធីតា ពិតជាបានមិនបានរត់ទៅទីណា ហើយឲ្យសាកសួរ ទៅខាងភូមិ-ឃុំ និងសមត្ថកិច្ចថា តើជនជាប់ចោទឈ្មោះ [redacted] ធីតា ពិតជានៅផ្ទះឬក៏អត់? បន្ទាប់ពី បានដឹងថាជនរងគ្រោះត្រូវបានស្លាប់ហើយនោះ។

៥. ផ្អែកតាមលទ្ធផលការសួរដេញដោលនាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ និង ការពិនិត្យនូវភស្តុ តាងជាឯកសារផ្សេងៗក្នុងសំណុំរឿងនេះឃើញថា បើទោះបីជា ជនជាប់ចោទឈ្មោះ [redacted] ធីតា បាន ព្យាយាមឆ្លើយបដិសេធយ៉ាងណាក៏ដោយ។ ប៉ុន្តែ បើតាមអង្គហេតុនិងភស្តុតាងត្រូវបានបញ្ជាក់ឲ្យដឹងថា តាមចម្លើយរបស់ឈ្មោះ [redacted]ធហារ ដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ចនាថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០០៥ ថា "...*ឈ្មោះ* [redacted] *មុត និងមនុស្ស ៣ (បី) នាក់ នេះបណ្តើរគ្នាដើរទៅទិសខាងត្បូងបាត់ទៅ*



CS CamScanner

ហើយចំពោះមនុស្ស ៣ (បី) នាក់ នេះមានអាយុ ប្រហាក់ប្រហែលនិងឈ្មោះ [redacted] មុត ក្រោយបន្តិចមកខ្ញុំក៏ដើរមកផ្ទះខ្ញុំមក ចំពោះរឿងហេតុយ៉ាងណាទៀតខ្ញុំបាទពុំបានដឹងទេ។ លុះដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោងប្រហែល១០ព្រឹកស្រាប់តែដំណឹងថា ឈ្មោះ [redacted]មុត បានស្លាប់អណ្តែតទឹកព្រែកសំបួរ ពុំដឹងមូលហេតុ" (ឯកសារលេខ៩/២)។ ខណៈដែលតាមសាក្សីបំភ្លឺឈ្មោះ [redacted]សាមុត និងឈ្មោះ [redacted] មួន បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅពេលផឹកជនរងគ្រោះឈ្មោះ [redacted]មួន បានផឹកជាមួយឈ្មោះ [redacted]តេនា ឈ្មោះ [redacted]ជីតា និងឈ្មោះ [redacted]ប្រុស (ឯកសារលេខ៨/២និងលេខ១០/២)។ ទន្ទឹមនឹងដែរ តាមសក្ខីកម្មសាក្សីឈ្មោះ [redacted]រុន បានឆ្លើយឲ្យដឹងថា "...ក្រោយមកស្រាប់តែមានឈ្មោះ [redacted]ប្រាប់ថាយប់មិញមានគេវាយគ្នានៅមុខផ្ទះគាត់ ហើយគាត់ចេញទៅមើលឃើញឈ្មោះ [redacted] តេនា ឈ្មោះ [redacted] ជី និងឈ្មោះ [redacted]ប្រុស ហៅ ក្តីប កំពុងឈរនៅទីនោះហើយពួកវាឆ្លើយថា បន្លែងគ្នាលេង..." (ឯកសារលេខ២២/២)។ មិនតែប៉ុណ្ណោះ បើតាមចម្លើយឈ្មោះ [redacted]មួន នៅជំណាក់កាលអយ្យការថា "...ពេលធ្វើបុណ្យប្អូនរួចទើបដឹងថាអ្នកដែលសម្លាប់ប្អូនខ្ញុំមានគ្នា ៣ (បី) នាក់គឺឈ្មោះ [redacted] តេនា ហៅ ឆក [redacted]ជីតា, [redacted]ប្រុស នៅភូមិជ្រោយខ្សាច់ ឃុំបាក់ដាវ។ អ្នកទាំង ៣ (បី) នេះបានគេចខ្លួនតាំងពីយប់កើតហេតុម្លេះ..."(ឯកសារលេខ២០/២)។ ម្យ៉ាងវិញទៀត បើពិនិត្យលើមូលហេតុក្នុងពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted]ជីតា ត្រូវបានជនជាប់ចោទបានជាប្តឹងឧទ្ធរណ៍ដោយលើកមូលហេតុថា "សាលាដំបូងខេត្តកណ្តាលដាក់ទោសទណ្ឌលើរូបខ្ញុំបាទធ្ងន់ធ្ងរពេក" (ឯកសារលេខ៥៤)។ ចំណុចនេះទោះបីជាតិចឬច្រើន ជាចំណែកមួយដែលឆ្លុះបញ្ចាំងនូវការមិនបដិសេធយ៉ាងដាច់អហង្ការពីសំណាក់សាមីជនជាប់ចោទ ដូចអ្វីដែលជនជាប់ចោទបានឆ្លើយនៅចំពោះមុខសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញទេ។ ការណ៍នេះមិនទាន់ពិចារណា ពាក្យស្នើសុំឲ្យពិនិត្យកស្តុតាងលេខ ២៥៩៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]ជីតា ដោយដាក់លិខិតបញ្ជាក់លោកមេឃុំក្នុងខ្លឹមសារថា "...ឈ្មោះ [redacted]ជីតា ត្រូវមានទោសនៅមន្ទីរឃុំឃាំង ... គ្រួសារនេះសព្វថ្ងៃលំបាកវេទនាណាស់។ អាស្រ័យ ដូចលិខិតបញ្ជាក់ខាងលើនេះ សូមលោកមានសមត្ថកិច្ចមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ..."។ លើសពីនេះទៀតអង្គហេតុក្នុងសំណុំរឿងនេះ ត្រូវបានកើតឡើងតាំងពីថ្ងៃទីខែតុលា ឆ្នាំ២០០៥ ហើយជនជាប់ចោទឈ្មោះ គុយ ជីតា និងបក្សពួក ២ (ពីរ) រូបផ្សេងទៀត បានគេចខ្លួនពីមូលដ្ឋានរហូតមក។ យ៉ាងណាមិញ ក្រោយពីសមត្ថកិច្ចចាប់ឃាត់ខ្លួនឈ្មោះ [redacted] ជីតា បាននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ទើបបងរបស់ជនរងគ្រោះឈ្មោះ [redacted]រ៉ែន ភេទ ប្រុស អាយុ ៥៨ ឆ្នាំ បានដាក់ពាក្យសុំដកពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ទៅវិញ។ ដោយក្នុងលិខិតនោះបានលើកឡើងថា "... ក្រោយមកមានសាក្សីប្រជាពលរដ្ឋបំភ្លឺថា មុនកើតហេតុឃើញប្អូនថ្លៃខ្ញុំនេះមានជម្លោះជាមួយមនុស្សចំនួន ៣ (បី) នាក់ ក្នុងនោះមានឈ្មោះ [redacted] ជីតា ភេទ ប្រុស អាយុ ២១ ឆ្នាំ ទើបខ្ញុំសម្រេចដាក់ពាក្យបណ្តឹងតែម្តង។ ក្រោយកើតហេតុឈ្មោះ [redacted]ជីតា ពុំបានគេចខ្លួនទៅណាទេ ដោយសារឈ្មោះនេះអះអាងថា ខ្លួនពុំមែនជាអ្នកប្រព្រឹត្ត ហើយគ្រួសាររបស់ឈ្មោះ [redacted]ជីតា ក៏បានមកពន្យល់ខ្ញុំថា កូនរបស់គាត់មិនមែនជាអ្នកបង្កទេនិងស្នើសុំខ្ញុំឲ្យដកពាក្យបណ្តឹងវិញ ទើបមកដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ឈ្មោះ [redacted] ជីតា ត្រូវបានសមត្ថកិច្ចចាប់ខ្លួន..." (ឯកសារលេខ៤៣/៤ )

៦. ដោយឡែកចំពោះសាវតាជាតិជនល្មើសត្រូវបានលោក[redacted]ហួ មេឃុំបាក់ដាវបានចេញលិខិតបញ្ជាក់សាវតាជាតិជនល្មើសថា "*...ឈ្មោះ គុយ ធីតា កេទ ប្រុស អាយុ ២១ ឆ្នាំ ...*" គឺតាំងពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ មកម្លេះ (*ឯកសារលេខ១៨/២*)។ បើតាមដំណើរការនីតិវិធីក្នុងសំណុំរឿងនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] ធីតា រូបនេះ ត្រូវបានចៅក្រមស៊ើបអង្កេតនាពេលនោះបានចេញដីកាស្វែងរកចាប់ខ្លួនឈ្មោះ [redacted] ធីតា តាមរយៈដីកាលេខ ០១៧ដ.ក.ស.ច.ខ.០៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ (*ឯកសារលេខ២៣/៨*)។ ខណៈដល់នីតិវិធីជំនុំជម្រះ តុលាការបានកោះហៅឈ្មោះ [redacted]ធីតា តែត្រូវបានលោកអនុសេនីយ៍ទោ ឈឹម សុខវិខ បានចារជាលាយលក្ខណ៍អក្សរលើដីកាកោះ នាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយបានបញ្ជាក់ថា "*ក្រោយពីធ្វើសកម្មភាពលួច ជនល្មើសបានរត់គេចខ្លួនចេញពីមូលដ្ឋានបាត់*" (*ឯកសារលេខ២៧/១៤*)។ ជាក់ស្តែង អំណោះក្រោយមកទើបតែនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ទើបកម្លាំងសមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ[redacted]ធីតា បាននៅវេលាម៉ោង ១៣ និង ០០ នាទី តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបអង្កេតលេខ ០១៧ ដ.ក.ស.ច.ខ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦(*ឯកសារលេខ៣៩/៣ និងលេខ៤០*)។ ផ្អែកតាមដំណើរការនីតិវិធីដែលរងចំណាត់ការតាមលំហូរបែបនេះ ក្រុមប្រឹក្សាយល់ឃើញថា ពុំមានភាពចាំបាច់ធ្វើការចាត់របៀប តាមការកត់សម្គាល់របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជា តំណាងមហាអយ្យការដែរ ដែលបានលើកឡើងថា "*...ស្នើឲ្យធ្វើការចាត់របៀបដើម្បីដឹងថា ជនជាប់ចោទពិតជាមិនបានរត់ទៅទីណា ហើយឲ្យសាកសួរទៅខាងភូមិ-ឃុំនិងសមត្ថកិច្ចថា ជនជាប់ចោទឈ្មោះ [redacted] ធីតា ពិតជានៅផ្ទះឬក៏អត់ បន្ទាប់ពីដឹងថា ជនរងគ្រោះត្រូវបានស្លាប់រួចមក*"។

៧. ផ្អែកលើសម្អាងហេតុត្រង់ ចំណុចទី ៥ និង ចំណុចទី ៦ ខាងលើនេះ ក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted]ធីតា កេទ ប្រុស អាយុ ២១ ឆ្នាំ រូបនេះ ពិតជាប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់មែននាពេលកន្លងមក។

៨. មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ[redacted]ធីតា កេទ ប្រុស អាយុ ២១ ឆ្នាំ (អត្តសញ្ញាណលម្អិតក្នុងសំណុំរឿង) ពីបទ មនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលាឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៩. សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល ដែលបានសម្រេចសេចក្តីកន្លងមកនេះឃើញថា មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ទាំងស្រុងហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ពិចារណានិងសម្រេចតម្កល់ទុកជាបានការ ដោយហេតុថា ការសម្រេចមានលក្ខណៈសមទណ្ឌោរួចរាល់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។



CS CamScanner

២. តម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការ។

៣. បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ធីតា តាមនីតិវិធីច្បាប់។

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីតា ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។

ទុកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា

[redacted] [redacted] [redacted] [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សាលាដំបូងខេត្តកណ្ដាល ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]